ភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៣

# សេចក្តីសំរេច លេខ ១១ សសរ
# រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

* * * *

- យោងព្រះរាជក្រឹត្យរបស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋ នៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣
- ផ្អែកតាមសំណូមពរចាំបាច់

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការមួយ ដើម្បីរៀបចំឡើងវិញ និងពង្រីកព្រលានយន្តហោះពោធិចិនតុង ។

**ប្រការ ២ :** គណៈកម្មការនេះមានសមាសភាពដូចតទៅ ÷

| | | |
|---|---|---|
| ១. លោក ម៉ម សុជាណា | ទីប្រឹក្សាផ្ទាល់របស់ឯកឧត្តមសហប្រធានរដ្ឋាភិបាល ជាតិបណ្តោះអាសន្នកម្ពុជា | ជាប្រធាន |
| ២. លោក ប៉ុក សំអឿល | ទីប្រឹក្សាព្រះអង្គស្តេចក្រុមហ្លួង | ជាអនុប្រធាន |
| ៣. លោកតំណាងក្រសួងសាធារណៈការ | | ជាសមាជិក |
| ៤. លោកតំណាងក្រសួងហិរញ្ញវត្ថុ | | ជាសមាជិក |
| ៥. លោកតំណាងក្រសួងដឹកជញ្ជូន | | ជាសមាជិក |
| ៦. លោកតំណាងនាយកដ្ឋានអាកាសចរស៊ីវិលកម្ពុជា | | ជាសមាជិក |

**ប្រការ ៣ :** គណៈកម្មការនេះមានភារកិច្ចលើកគំរោង និង រៀបចំឡើងវិញ និង ពង្រីកព្រលានយន្តហោះពោធិចិនតុង អោយសមស្របទៅតាមស្ថានភាព នៃប្រទេសជាតិ និង ខ្នាតអន្តរជាតិ ។ រាល់គំរោងប្លង់ទាំងអស់ត្រូវឆ្លងមតិ សហប្រធានរដ្ឋាភិបាលជាតិបណ្តោះអាសន្ន ពិនិត្យសំរេចមុន និង អនុវត្ត ។

**ប្រការ ៤ :** គណៈកម្មការនេះមានសិទ្ធិអញ្ជើញតំណាងក្រសួងពាក់ព័ន្ធមកប្រជុំ និង ចូលរួមក្នុងការពិនិត្យដោះស្រាយការងារខាងលើនេះ ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណៈ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងដឹកជញ្ជូន ប្រធាន នាយកដ្ឋានអាកាសចរស៊ីវិលកម្ពុជា បណ្ដាក្រសួងដែលមានការពាក់ព័ន្ធ និង អស់លោកដែលមានឈ្មោះចែងក្នុងប្រការ ២ ត្រូវអនុវត្តតាមសេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខានេះតទៅ ។

សហប្រធាន

រដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជា

ព្រះហស្ថលេខា និង ហត្ថលេខា

ស្ដេចក្រុមហ្លួង នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * * *

ភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៣

## សេចក្ដីសំរេច លេខ ១២ សសរ

## ស្ដីពីការផ្ទេរ និង ប្រើប្រាស់ត្រារបស់ក្រសួង ស្ថាប័ន រដ្ឋអំណាចគ្រប់ជាន់ថ្នាក់

* * * *

## រដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា

- បានឃើញក្រឹត្យរបស់សម្ដេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋ នៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដាឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា
- យោងសារាចរ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពីនាមប្រទេស ទង់ជាតិ ភ្លេងជាតិ និង ព្រះរាជលញ្ឆករ
- ពិនិត្យតាមសំណូមពរចាំបាច់ ក្នុងសភាពការណ៍បច្ចុប្បន្ន